00165512

C26/I/13

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)**

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:**

ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៣ មីនា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 03 / 2008
ម៉ោង (Time/Heure): 15 h 05 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

---

សាធារណៈ:

**ដីកាសម្រេចស្តីពីការស្នើសុំសវនាការសាធារណៈរបស់មេធាវី ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងស្តីពីការស្នើសុំរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យមានការលុបចេញនូវកថាខ័ណ្ឌមួយចំនួន ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Robert PETIT
លោក ពេជ្រ សម្បត្តិ
លោក Alex BATES

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីការពារក្តី**

លោក សាយ [illegible]
លោក Jacques VERGÈS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

00165513



C26/I/13

**អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អវតក"**

**យល់ឃើញថា** សហមេធាវីជនត្រូវចោទ បានដាក់ប្រភេទឯកសារបណ្តឹងឧទ្ធរណ៍ដែលធ្វើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ("បណ្តឹងឧទ្ធរណ៍") ជាប្រភេទឯកសារ "ការសម្ងាត់" ។

**យល់ឃើញថា** ចម្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ តបទៅនឹងបណ្តឹងឧទ្ធរណ៍ (ចម្លើយតប) ក៏ត្រូវបានដាក់ជូនមកជាប្រភេទឯកសារ "ការសម្ងាត់" ហើយបានស្នើសុំឲ្យមានសវនាការជាអសាធារណៈដោយផ្អែកលើមូលហេតុថា បណ្តឹងឧទ្ធរណ៍ផ្តោតសំខាន់ទៅលើការតវ៉ាចំពោះភាពគ្រប់គ្រាន់នៃភស្តុតាង និងពាក់ព័ន្ធនឹងការពិភាក្សាដេញដោលលំអិតស្តីពីអង្គហេតុដែលមាននៅក្នុងសំណុំរឿង ។

**បានឃើញ** ឯកសាររបស់សហមេធាវីចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានចំណងជើង **"បញ្ហាគ្មានសវនាការជាសាធារណៈ ដែលលើកឡើងដោយសហព្រះរាជអាជ្ញាក្នុងចម្លើយរបស់ខ្លួនចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧"** ដែលក្នុងនោះសហមេធាវីបានស្នើសុំឲ្យមានសវនាការជាសាធារណៈ និងប្រកាសថាសហមេធាវីពុំមានការជំទាស់ឡើយចំពោះការដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនជាសាធារណៈនៅថ្ងៃសវនាការ។

**បានឃើញ** សេចក្តីបង្គាប់ដល់សហព្រះរាជអាជ្ញាឲ្យដាក់ចម្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលបង្គាប់ឲ្យសហព្រះរាជអាជ្ញាបង្ហាញពីជំហររបស់ខ្លួនចំពោះបញ្ហាដែលលើកឡើងដោយសហមេធាវី ។

**បានឃើញ** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ហាសវនាការជាសាធារណៈចំពោះបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ("ចម្លើយតបស្តីពីបញ្ហាសវនាការជាសាធារណៈ") ដែលក្នុងនោះសហព្រះរាជអាជ្ញាបានបញ្ជាក់សារជាថ្មីម្តងទៀត អំពីការអះអាងរបស់ខ្លួនទាក់ទងនឹងតម្រូវការសវនាការអសាធារណៈ ប៉ុន្តែប្រកាសថាសហព្រះរាជអាជ្ញា "ពុំមានការជំទាស់ទេចំពោះការបើកសវនាការជាសាធារណៈ ទាក់ទងនឹងសេចក្តីសំអាងដែលពាក់ព័ន្ធនឹងទទ្បីករណ៍សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន តាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ដូចដែលអង្គបុរេជំនុំជម្រះធ្លាប់បានអនុវត្តរហូតមកដល់សព្វថ្ងៃនេះ" ។

**យល់ឃើញថា** ក្នុងចម្លើយតបស្តីពីបញ្ហាសវនាការជាសាធារណៈ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការលុបចេញនូវកឋាខ័ណ្ឌ ១៨, ២៣, ៣២, ៤៤, ៤៥, និង ៤៨-៥៥ ដោយរាប់បញ្ចូលទាំងកឋាខ័ណ្ឌ ៥៥ ផងដែរ ដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ដើម្បីប្រើប្រាស់សម្រាប់សាធារណៈផង ដោយហេតុថាកឋាខ័ណ្ឌទាំងនោះបានយោងទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដែលពោលអះអាងអំពីភស្តុតាងនានាដែលជាក់លាក់ ។

**យល់ឃើញថា** វិធាន ៧៧(៥) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) ចែងថា សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវតែធ្វើឡើងជាអសាធារណៈ លើកលែងតែមានចែងផ្សេងក្នុងអនុវិធាន ៦ ។

**យល់ឃើញថា** បណ្តឹងឧទ្ធរណ៍ មានជាប់ពាក់ព័ន្ធនឹងការពិភាក្សាដេញដោលលំអិត ស្តីពីភស្តុតាងដែលមានក្នុងសំណុំរឿង ។

**យល់ឃើញថា** វិធាន ៥៦ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ចែងថា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់ ។

**យល់ឃើញថា** មាត្រា ៣៤ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលចែងថា “អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើឡើងជាសារធារណៈ” ដែលអនុវត្តចំពោះដំណាក់កាលនៃការជំនុំជម្រះក្តី មិនមែនក្នុងកំឡុងពេលនៃការស៊ើបសួរទេ ។

**អនុលោមតាម** វិធាន ៧៧(៥) និង (៦) នៃវិធានផ្ទៃក្នុង និងមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក/០១/២០០៧ ។

**ដូច្នេះសម្រេច**

១. សវនាការស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវធ្វើឡើងជា**អសាធារណៈ** លើកលែងតែផ្នែកដែលទាក់ទងនឹងការពិភាក្សាដេញដោល អំពីមូលដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ដែលត្រូវធ្វើឡើងជា **សាធារណៈ** ។

២. អនុញ្ញាតឲ្យសហមេធាវីជនត្រូវចោទដាក់សម្រង់ថ្មីនៃបណ្តឹងឧទ្ធរណ៍សម្រាប់សាធារណជន ដោយដកចេញនូវកថាខ័ណ្ឌ ១៨, ២៣, ៣២, ៤៤, ៤៥ និង ៤៨-៥៥ រាប់បញ្ចូលទាំងកថាខ័ណ្ឌ ៥៥ សម្រាប់អង្គបុរេជំនុំជម្រះផ្សព្វផ្សាយជាសាធារណៈ ។ ៕

ភ្នំពេញ, ថ្ងៃទី៣ ខែមីនា ឆ្នាំ ២០០៨

**អង្គបុរេជំនុំជម្រះ** | **ប្រធានអង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ធុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

PRE-TRIAL CHAMBER * E.C.C.C * CHAMBRE PRELIMINAIRE